# ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា

CAMBODIA WATCHDOG COUNCIL INTERNATIONAL

គ្រីស្ទានសាន់ (ន័រវេស៍) ថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២០

## សេចក្ដីអំពាវនាវ

### ពលរដ្ឋខ្មែរ គប្បីផ្អាកចូលរួមពិធីជួបជុំ និងពិធីបុណ្យទាន ជាការរួមទប់ស្កាត់ជំងឺ Covid-19

ចំណាត់ការទប់ស្កាត់របស់ក្រសួងសុខាភិបាលកម្ពុជា ប្រយុទ្ធប្រឆាំងមេរោគកូរ៉ូណា ឬកូវីដ-១៩ (Covid-19) នៅមានកម្រិត ហើយមិនទាន់បានរំលឹកពលរដ្ឋខ្មែរ ឲ្យចូលរួមទប់ស្កាត់តាមរយៈពិធីជួបជុំនានា ដូច្នេះអាចជាសេចក្ដីព្រួយបារម្ភទ្វេដង ដែលនាំឲ្យមានការរីករាលដាលមេរោគនេះ បើទោះបីរដ្ឋបាលដឹកនាំរបស់លោក ហ៊ុន សែន បានបញ្ជាឲ្យបិទទ្វារសាលារៀន នៅក្រុងសៀមរាប រាជធានីភ្នំពេញ និងកន្លែងពាក់ព័ន្ធមេរោគឆ្លងមួយចំនួនក្ដី។

បន្ថែមលើការណែនាំរបស់ក្រសួងសុខាភិបាល ក្នុងការចូលរួមទប់ស្កាត់មេរោគកូរ៉ូណា ***គប្បីពលរដ្ឋខ្មែរ ជ្រើសរើសយកការសម្រាកនៅគេហដ្ឋានរៀងខ្លួន បើគ្មានការចាំបាច់បន្ទាន់ ទៅធ្វើការងារនៅកន្លែងធ្វើការ ឬការិយាល័យ។ ការចេញខាងក្រៅផ្ទះ គួរគប្បីត្រូវផ្អាកជាបណ្ដោះអាសន្ន ដូចជាជួបជុំមិត្តភក្តិ ឬទៅក្លឹបកំសាន្ត, មណ្ឌលកំសាន្ត, ទៅចូលរួមពិធីជប់លៀង, ចូលរួមពិធីភ្ជាប់ពាក្យ ឬអាពាហ៍ពិពាហ៍, និងពិធីបុណ្យទាននានា តាមគេហដ្ឋានក្ដី ឬតាមទីវត្តអារាមក្ដី*** ជាដើម។ល។

ការជួបប្រាស្រ័យទាក់ទងគ្នា ជាលក្ខណៈមិត្តិភក្តិ ឬជាដៃគូការងារ ***គួរតែមិនត្រូវឲ្យច្រើនជាង ២ នាក់ទៅ ៣ នាក់ ហើយត្រូវរក្សាចម្ងាយពីគ្នា ពី ១ ម៉ែត្រ ទៅ ១,៥០ ម៉ែត្រ។***មុនពេលជួបគ្នា ត្រូវលាងសម្អាតដៃ ដោយសាប៊ូលាងដៃ ឬអាល់កុល ហើយនៅក្រោយពេលជួបគ្នា ក៏ត្រូវលាងសម្អាតដៃដែរ។ ចូរយក«ការសំពះជម្រាបសួរ» ជាប្រពៃណីដ៏ល្អរបស់ខ្មែរ ធ្វើជាគោលការណ៍ ក្នុងការជួបភ្ញៀវ ទាំងវិស័យការងារ និងការជួបគ្នាជាធម្មតា ដោយមិនត្រូវជួប«ចាប់ដៃ»ទេ។

មកទល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២០ នេះ ក្រសួងសុខាភិបាល បានប្រកាសដំណឹងផ្លូវការថា ***កម្ពុជា មានករណីឆ្លងមេរោគកូរ៉ូណា ឬ Covid-19 កើនឡើងដល់ ២៤ នាក់ហើយ*** ដែលជាការបង្កើនសេចក្ដីព្រួយបារម្ភបន្ថែមទៀត សម្រាប់ពលរដ្ឋខ្មែរ ខណៈដែលប្រព័ន្ធសុខាភិបាលខ្មែរ នៅទន់ខ្សោយ និងគ្មានវិធានការច្បាស់លាស់ ព្រមទាំងធ្វើឲ្យឆកល្វេង ក្នុងការទប់ស្កាត់មេរោគដ៏កាចសាហាវនេះ តាំងពីដំបូងទី។

**ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ប្រធាន**

**ម៉ែន ណាត**

Address: Senterveien 54, Apartment 112, 4790 Lillesand, NORWAY /Contact nathamonin@gmail.com /
Hompage: https://cwcicambodia.net